01070030

002/19-09-2007-ECCC/TC
**E1/257**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 15 / 02 / 2015
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បតិ៍ ទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៥

## សវនាការលើភ័ស្តុតាង - ថ្ងៃ ២៣៨

រៀបចំដោយ៖ **សែ កុលវុឌ្ឍី** និង **Matthew McCARTHY**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, កញ្ញា ជា ស៊ីវហ៉ង, លោក Matthew McCARTHY |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, កញ្ញា សុង ឆវិន្ត, លោក Dale LYSAK, លោក Vincent de WILDE d'ESTMAEL, |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួន), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE, លោក សួន វិសាល |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក ឡោ |

| |
|---|
| ជុនធី, លោក វ៉ែន ពៅ, លោកស្រី ជេត វណ្ណលី, លោកស្រី ម៉ុច សុវណ្ណារី, លោកស្រី Martine JACQUIN, លោក Mahesh Rai |
| សាក្សី/ដើមបណ្ដឹង៖ លោក សយ សែន (2-TCCP-271) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ កញ្ញា សុក សុភ័គមណីកា, លោក នូ មនោរត្ន័, លោក វ៉ាត សុម៉ៅ, កញ្ញា ពេជ ចរិយា, កញ្ញា តូច តន់នាវី, លោក Mario D'ALESSANDRO |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៦.០៥ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១៥ | បញ្ចប់ម៉ោង៖ ១០.៣៥ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៤៥ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៣០ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ២០ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០០ | ០៩.០៥ |
| ការស្នើសុំលះបង់សិទ្ធិរបស់ នួន ជា ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការ | មេធាវីការពារក្ដី នួន ជា<br>អង្គជំនុំជម្រះ | ០៩.០៥ | ០៩.០៧ |
| ការស្នើសុំទទួលស្គាល់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីអន្តរជាតិថ្មី | មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ | ០៩.០៨ | ០៩.១០ |
| ការជំទាស់ចំពោះការដាក់ឈ្មោះមេធាវីប្រចាំការនៅលើទំព័រខាងមុខថាជាមេធាវីការពារឲ្យ ខៀវ សំផន | មេធាវីការពារក្ដី ខៀវ សំផន<br>សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ | ០៩.១១ | ០៩.១៣ |
| ការបន្តតាំងសំណួរទៅកាន់សាក្សី សយ សែន (2-TCCP-271) | សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ<br>មេធាវីការពារក្ដី នួនជា | ០៩.១៥<br>១០.៤៥<br>១៥.៣៨ | ១០.៤៥<br>១៥.៣៨<br>១៦.០៤ |

| | | | |
|---|---|---|---|
| ការស្នើសុំអោយមានសវនាការជាអសាធារណៈ | មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី<br>មេធាវីការពារក្តី នួន ជា<br><br>មេធាវីការពារក្តី ខៀវ សំផន<br>អង្គជំនុំជម្រះ | ១១.៣៥<br>១៣.៣៦<br>១១.៣៩<br>១៣.៣៩<br>១១.៤១<br>១១.៤៣ | ១១.៣៨<br>១៣.៣៨<br>១១.៤០<br>១៣.៤០<br>១១.៤៣<br>១១.៤៤ |
| សេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំធ្វើសវនាការជាអសាធារណៈ | អង្គជំនុំជម្រះ | ១៣.៤២ | ១៣.៤៣ |
| ការពិភាក្សាអំពីសំណើសុំធ្វើសវនាការជាអសាធារណៈ | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>ដើមបណ្តឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ១៣.៤៥ | ១៤.២៦ |
| សេចក្តីសម្រេចលើសំណើសុំរបស់មេធាវីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីធ្វើសវនាការជាអសាធារណៈ | អង្គជំនុំជម្រះ | ១៥.០៥ | ១៥.១០ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធី បន្ទាប់មកក្រឡាបញ្ជីបានរាយការណ៍ថាគ្រប់ភាគីទាំងអស់មានវត្តមាន លើកលែងតែមេធាវីអន្តរជាតិការពារក្តីឲ្យ ខៀវ សំផន អវត្តមាន និងជនជាប់ចោទ នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួន ខាងក្រោមសាលសវនាការ។

**<u>ការស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការរបស់ នួន ជា</u>**

ជនជាប់ចោទ នួន ជា តាមរយៈមេធាវីការពារក្តីរបស់ខ្លួន បានស្នើសុំលះបង់សិទ្ធចូលរួមកិច្ចដំណើរការនីតិវិធីសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ។ អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើសុំនេះ។

**ការស្នើសុំទទួលស្គាល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិថ្មី**

មេធាវីជាតិនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំទទួលស្គាល់មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីថ្មីមួយរូប។ អង្គជំនុំជម្រះសម្រេចទទួលស្គាល់ លោក Mahesh Rai ជាមេធាវីអន្តរជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់គោលបំណងនៃដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ។

**ការជំទាស់ចំពោះការដាក់ឈ្មោះមេធាវីប្រចាំការនៅទំព័រជាមួយមេធាវីការពារក្តី ខៀវ សំផន**

មេធាវីការពារក្តី ខៀវ សំផន បានស្នើសុំឲ្យអង្គជំនុំជម្រះណែនាំដល់សហព្រះរាជអាជ្ញាមិនឲ្យបញ្ចូលឈ្មោះមេធាវីប្រចាំការទៅក្នុងក្រុមមេធាវីការពារក្តីឲ្យលោក ខៀវ សំផន នៅក្នុងការដាក់ឯកសាររបស់ពួកគេនៅទំព័រដំបូងនៃក្រុមមេធាវីការពារក្តី ខៀវ សំផន។

**ការបន្តតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី សយ សែន** (2-TCCP-271)

សហព្រះរាជអាជ្ញាបានបន្តការតាំងសំណួររបស់ខ្លួន បន្ទាប់មក អង្គជំនុំជម្រះ មេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវសំផន បានធ្វើការតាំងសំណួរបន្ត។

**ការស្នើសុំអោយមានសវនាការជាអសាធារណៈរបស់តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញពីការបារម្ភពីសុវត្ថិភាពរបស់ខ្លួន មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឲ្យអង្គជំនុំជម្រះស្តាប់សក្ខីកម្មដើមបណ្តឹង សយ សែន នៅក្នុងសវនាការជាអសាធារណៈ។ មេធាវីការពារក្តី នួន ជា និង ខៀវ សំផន បានធ្វើការជំទាស់ដោយលើកឡើងថាការស្នើសុំនេះមិនមានមូលដ្ឋានត្រឹមត្រូវ និងមិនមូលហេតុសមស្រមនោះទេ។

បន្ទាប់ពីពេលសម្រាកថ្ងៃត្រង់ អង្គជំនុំជម្រះបានស្តាប់មតិយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ហើយបានបង្គាប់ឲ្យផ្នែកសោតទស្សន៍ឲ្យកាត់ផ្តាច់នូវប្រព័ន្ធសំឡេងចេញទៅសាលសវនាការជាសាធារណៈនៅខាងក្រៅ។ បន្ទាប់មកអង្គជំនុំជម្រះឈប់សម្រាកដើម្បីពិភាក្សាសម្រេច។

អង្គជំនុំជម្រះបានលើកឡើងថា អង្គជំនុំជម្រះមិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីសម្រេចទៅលើសំណើនេះទេ ហើយសម្រេចពន្យាពេលសម្រេចលើសំណើសុំវិធានការការពារនេះ។ អង្គជំនុំជម្រះ នឹងស្នើឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញធ្វើរបាយការណ៍វាយតម្លៃពីបញ្ហានេះ។ ដើម្បីការពារនូវគោលបំណងនៃសំណើសុំនេះ អង្គជំនុំជម្រះមិនអនុញ្ញាតិឲ្យភាគីតាំងសំណួរដែលទាក់ទង នឹងអត្តសញ្ញាណរបស់កម្មាភិបាលផ្សេងៗនៅមន្ទីរសន្តិសុខក្រាំងតាចាន់ និងជូនដំណឹងទៅដើមបណ្តឹងថា ដើមបណ្តឹងអាចបដិសេធមិនឆ្លើយតបទៅនឹងសំណួរណាដែលពាក់ព័ន្ធនឹងបុគ្គលិកនៅក្រាំងតាចាន់។

**សេចក្តីសម្រេចលើសំណើសុំធ្វើសវនាការជាអសាធារណៈ:**

អង្គជំនុំជម្រះទទួលយកសំណើសុំរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការបន្តធ្វើសវនាការជាអសាធារណៈដើម្បីផ្តល់ឱកាសឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពន្យល់ពីមូលដ្ឋាននៃសំណើសុំនេះ។ អង្គជំនុំជម្រះបានបង្គាប់ឱ្យអង្គភាពសោតទស្សន៍កាត់ផ្តាច់ប្រព័ន្ធសោតទស្សន៍ទៅសាលសវនាការខាងក្រៅ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| លេខ E3 | លេខ កសចស | | ចំណងជើង | ចំណាត់ថ្នាក់ | ERN ខ្មែរ | ERN អង់គ្លេស | ERN បារាំង |
|---|---|---|---|---|---|---|---|
| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
| E3/5214 | | 00223055-00223070 00225500-00225513 00702886-00702902 | [Corrected 1] Written Record of Interview of SÂY Sen | P | 00223058 00223064 00223068 | 00225503 00225508 00225511 | 00702889 00702895 00702899 |
| E327/4 | | 01060742-01060748 01060737-01060741 N/A | Co-Prosecutor's objections and reservations to parties' proposed documents list in response to the Trial Chamber's memorandum E327 and request to obtain documents | P | 01060742-01060748 | 01060737-01060741 | N/A |
| E321/2 | | 01044402-01044412 01044384-01044391 01044392-01044401 | Decision on the Appointment of Court Appointed Standby Counsel for KHIEU Samphan | P | 01044402-01044412 | 01044384-01044391 | 01044392-01044401 |
| E3/4095 | | 00271089-00271131 00747236-00747298 00721205-00721272 | 5th confession entitled "Contemptible traitors POL Pot and IENG Sary" | P | 00271090 00271091 | 00747237 | 00721206 |
| E3/4101 | | 00271034-00271039 00322124-00322129 00854216-00854221 | Report to the Party on Kim Vanny, a Chinese | P | 00271039 | 00322129 | 00854221 |
| E3/5827 | | 00270855-00270897 00866424- | [Partial.T] Victim's background | P | 00270883 00270884 00270886 | 00866446 00866447 00866450 | 00872822 00872824 00872829 |

01070035



| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00866463<br>00872799-<br>00872835 | | | 00270891 | 00866456 | |
| E3/5841 | D22/1370 | 00527699-<br>00527714<br>N/A<br>01057605-<br>01057614 | Demande de constitution de partie civile de SÂY Sèn 08-VU-00071 | P | 00527705 | N/A | 01057607 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តតាមដានដំណើរការសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោម។
- សេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងការអនុញ្ញាតអោយមានសវនាការជាអសាធារណៈដើម្បីស្តាប់សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី នឹងបង្គាប់ឲ្យផ្នែកសោតទស្សន៍កាត់ផ្តាច់សម្លេងចេញទៅសាលសវនាការខាងក្រៅ។ បន្ទាប់ពីសម្រាកនិងការពិភាក្សា អង្គជំនុំជម្រះបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់សម្លេងចេញទៅសាលសវនាការខាងក្រៅវិញ។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនគាត់មកសាលសវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ។

<u>កាលវេលាសវនាការបន្ត</u>

សវនាការនឹងបន្តទៅថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ គុលឧត្តរ៍ Matthew McCARTHY**